***"តើមានបញ្ហាអ្វី បើខ្ញុំមិនអាចមានលទ្ធភាពលើការចំណាយ?"***

ក្រុមគ្រួសាររបស់អ្នកអាចមិនត្រូវបានបដិសេធចំពោះសេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូង ដោយផ្អែកលើការខ្វះលទ្ធភាពបង់ប្រាក់ធានារ៉ាប់រងរួមគ្នា សហធានារ៉ាប់រង ឬការដកហូតយកប្រាក់របស់អ្នក។ ការបំពេញសំណុំបែបបទដែលបានផ្តល់ជូនលោកអ្នក នឹងកំណត់សមត្ថភាពឬអសមត្ថភាពរបស់អ្នកចំពោះការបង់ប្រាក់។ ប្រសិនបើយើងខ្ញុំកំណត់ថាលោកអ្នកអាចបង់ថ្លៃចំណាយទាំងនេះ លោកអ្នកនឹងត្រូវទទួលខុសត្រូវចំពោះការបង់ប្រាក់ឱ្យពួកគេពេញលេញ។ FRC និងអ្នកផ្តល់សេវាកម្មរបស់អ្នក នឹងជួយអ្នកនៅក្នុងដំណើរការនេះ។

គ្រួសារមួយអាចស្នើសុំការកំណត់ឡើងវិញនូវសមត្ថភាពរបស់ពួកគេចំពោះការបង់ប្រាក់ធានារ៉ាប់រងរួមគ្នា សហធានារ៉ាប់រង ឬការដកហូតយកប្រាក់របស់ពួកគេ ឬថ្លៃឈ្នួលគ្រួសារប្រចាំខែរបស់ពួកគេគ្រប់ពេលវេលាដែលមានការប្រែប្រួលចំពោះប្រាក់ចំណូលឬការចំណាយរបស់ក្រុមគ្រួសារ។

ប្រសិនបើគ្រួសារមួយបានខកខានច្រើនជាង 90 ថ្ងៃក្នុងការបង់ប្រាក់ធានារ៉ាប់រងរួមគ្នា សហធានារ៉ាប់រង ឬការដកហូតយកប្រាក់របស់ពួកគេ ឬថ្លៃឈ្នួលគ្រួសារប្រចាំខែរបស់ពួកគេនោះ កម្មវិធី EI អាចផ្អាកសេវាកម្មនៃកម្មវិធី IFSP រហូតដល់ផែនការទូទាត់ប្រាក់ត្រូវបានបង្កើតឡើងដោយកម្មវិធី EI ។

***"ខ្ញុំគិតថាការធានារ៉ាប់រងរបស់ខ្ញុំបានចេញថ្លៃចំណាយលើសេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូង"។***

ផែនការធានារ៉ាប់រងសុខភាពមួយចំនួនអាចចេញថ្លៃសេវាកម្ម EI ខ្លះ រីឯផែនការធានារ៉ាប់រងសុខភាពផ្សេងទៀតមិនចេញថ្លៃឡើយ។ សេវាកម្ម EI នឹងដំណើរការដោយខ្លួនឯងជាមួយលោកអ្នក ដើម្បីកំណត់ការចូលរួមចំណាយរបស់គ្រួសារអ្នក

**សំណួរ ឬការព្រួយបារម្ភ?**

នាយកកម្មវិធីនៅកម្មវិធីអន្តរាគមន៍ចាប់ផ្តើមដំបូងរបស់អ្នក (EI) អាចឆ្លើយសំណួរណាមួយដែលអ្នកមានអំពីការចូលរួមចំណែកចំណាយលើគ្រួសារ (FCP) ឬសេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូង។



អ្នកសម្របសម្រួលធនធានក្រុមគ្រួសារ (FRC) របស់អ្នកគឺ៖

ទូរស័ព្ទ៖ ______________________________

កម្មវិធី៖ ______________________________

# សេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូងនៅរដ្ឋវ៉ាស៊ីនតោន

## ការចូលរួមចំណែកចំណាយលើគ្រួសារ (FCP)

Department of Early Learning
Early Support for Infants and Toddlers (ESIT)
P.O. Box 40970
Olympia, WA 98504-0970
ទូរស័ព្ទ៖ 360.725.3500

DEL 11-019d (8/13)

# សេវាកម្ម (EI) អន្តរាគមន៍ចាប់ផ្តើមដំបូងនៅរដ្ឋវ៉ាស៊ីនតោន

***"តើសេវាកម្ម (EI) អន្តរាគមន៍ចាប់ផ្តើមដំបូងមានតម្លៃប៉ុន្មាន?"***

មិនមានវិធីសាស្ត្រណាដែលដឹងពិតប្រាកដថានឹងត្រូវចំណាយប៉ុន្មានលើសេវាកម្ម EI របស់កូនអ្នកឡើយ។ យើងខ្ញុំមិនដឹងព័ត៌មាននោះរហូតទាល់តែយើងខ្ញុំពិភាក្សាជាមួយលោកអ្នក ហើយកំណត់នូវអ្វីដែលលោកអ្នកត្រូវការពិនិត្យមើល ដែលកើតមានឡើងចំពោះកូននិងគ្រួសាររបស់អ្នក ដោយសារការចូលរួមក្នុងការធ្វើអន្តរាគមន៍ចាប់ផ្តើមដំបូង។ សេវាកម្មដែលកូននិងគ្រួសាររបស់អ្នក នឹងទទួលបានដោយផ្អែកលើអាទិភាព ធនធាន ការព្រួយបារម្ភរបស់ក្រុមគ្រួសារអ្នក និងតម្រូវការរបស់កូនអ្នក។ ពួកគេនឹងត្រូវបានកំណត់ដោយលោកអ្នក និងក្រុមការងារដែលអ្នកកំពុងធ្វើការជាមួយ។ សេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូង មានលក្ខណៈបុគ្គលចំពោះកូននិងគ្រួសារនីមួយៗ។



***តើមានការចំណាយលើសេវាកម្មនានាឬទេ?***

ផ្នែក C នៃច្បាប់ស្តីពីអប់រំបុគ្គលដែលមានពិការភាព (IDEA) គឺជាច្បាប់សហព័ន្ធដែលណែនាំអំពីរបៀបផ្តល់ជូនសេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូង (EI) ។ IDEA អនុញ្ញាតឱ្យមានការចូលរួមចំណែកចំណាយលើគ្រួសារ (FCP) សម្រាប់សេវាកម្ម EI មួយចំនួន។ FCP រាប់បញ្ចូលការប្រើប្រាស់ការធានារ៉ាប់រងដោយក្រុមហ៊ុនឯកជន ឬដោយរដ្ឋរបស់ក្រុមគ្រួសារ។ តាមលក្ខខណ្ឌខ្លះ FCP អាចរាប់បញ្ចូលថ្លៃឈ្នួលក្រុមគ្រួសារផងដែរ។

***"ខ្ញុំគិតថាសេវាកម្មនានា មិនគិតថ្លៃឡើយ"។***

ផ្នែក C នៃ IDEA កំណត់ថាសកម្មភាព EI <u>មួយចំនួន</u> ត្រូវផ្តល់ជូនដោយឥតគិតថ្លៃដល់ក្រុមគ្រួសាររបស់អ្នក។ សកម្មភាពទាំងនោះរួមមាន៖

- ការស្វែងរកកុមារ (ការផ្សព្វផ្សាយស្វែងរកកុមារៗដែលអាចមានសិទ្ធិស្របច្បាប់ទទួលបាន EI) ។
- ការវាយតម្លៃនិងការប៉ាន់ប្រមាណ (ដើម្បីកំណត់ថាតើកុមារមានសិទ្ធិស្របច្បាប់ទទួលបាន EI ដែរឬទេ)។
- ការសម្របសម្រួលសេវាកម្ម (សកម្មភាពនានាដែលស្វែងរកប្រភពធនធានសម្រាប់ក្រុមគ្រួសារ) ។
- ការអភិវឌ្ឍផែនការសេវាកម្មក្រុមគ្រួសារដែលមានលក្ខណៈបុគ្គល (IFSP) និងការពិនិត្យឡើងវិញផែនការគ្រួសារ។
- សិទ្ធិគ្រួសារ (ត្រូវបានគេស្គាល់ថាជាការពារសុវត្ថិភាពតាមនីតិវិធី និងដំណើរការតាមនីតិវិធីត្រឹមត្រូវ) ។

***"តើខ្ញុំនឹងដឹងថា តើមានការចំណាយយ៉ាងដូចម្តេច?"***

សំណុំបែបបទដែលស្នើសុំឱ្យលោកអ្នកបំពេញនោះ នឹងជួយលោកអ្នកក្នុងការកំណត់ថាតើនឹងមានការចំណាយណាមួយលើសេវាកម្មឬអត់។ ប្រសិនបើលោកអ្នកយល់ព្រមលើសំណុំបែបបទនេះ ដើម្បីប្រើប្រាស់ការប្រើប្រាស់ការធានារ៉ាប់រងដោយក្រុមហ៊ុនឯកជន ឬដោយរដ្ឋរបស់អ្នក ហើយយល់ព្រមចំពោះការបង់ប្រាក់ធានារ៉ាប់រងរួមគ្នា សហធានារ៉ាប់រង ឬការដកហូតយកប្រាក់របស់អ្នកនោះ លោកអ្នកមិនចាំបាច់ផ្តល់ជូនព័ត៌មានហិរញ្ញវត្ថុណាមួយឡើយ។ ប្រសិនបើលោកអ្នកគិតថាលោកអ្នកមិនអាចបង់ប្រាក់ធានារ៉ាប់រងរួមគ្នា សហធានារ៉ាប់រង ឬការដកហូតយកប្រាក់របស់អ្នកនោះ ព័ត៌មានហិរញ្ញវត្ថុនឹងត្រូវផ្តល់ជូនដើម្បីកំណត់ថាតើនឹងមានការចំណាយណាមយយលើសេវាកម្មនានាឬទេ។

***"តើមានបញ្ហាអ្វី បើខ្ញុំជ្រើសរើសមិនផ្តល់ជូនព័ត៌មានអំពីប្រាក់ចំណូល ឬការធានារ៉ាប់រងសុខភាពរបស់ខ្ញុំ?"***

ក្រុមគ្រួសារនានាមានសិទ្ធិមិនផ្តល់ព័ត៌មានអំពីប្រាក់ចំណូលរបស់ពួកគេ ឬអនុញ្ញាតឱ្យកម្មវិធីបង់ថ្លៃវិក្កយបត្រសម្រាប់ការធានារ៉ាប់រងដោយក្រុមហ៊ុនឯកជន ឬដោយរដ្ឋរបស់ពួកគេ។ ប្រសិនបើលោកអ្នកជ្រើសរើសមិនផ្តល់ព័ត៌មានអំពីប្រាក់ចំណូលសូមដាក់ពាក្យសុំកម្មវិធីមេឌីឃេត Medicaid (បើមានសិទ្ធិស្របច្បាប់) ឬអនុញ្ញាតឱ្យកម្មវិធីបង់ថ្លៃវិក្កយបត្រសម្រាប់ការធានារ៉ាប់រងនោះ លោកអ្នកនឹងត្រូវបានគេកំណត់ថ្លៃគ្រួសារប្រចាំខែសម្រាប់សេវាកម្មនានា ប្រសិនបើមានការកំណត់ការចូលរួមចំណែកចំណាយលើគ្រួសារ (FCP) ដោយផ្អែកលើទំហំនិងចំណូលរបស់អ្នក។

ព័ត៌មានលម្អិតបន្ថែមអំពីការចំណាយលើគ្រួសារដែលអាចកើតមាននោះ ត្រូវបានផ្តល់ជូននៅក្នុងប្រព័ន្ធទូទាត់ប្រាក់ និងគោលនយោបាយស្តីពីថ្លៃសេវាដែលអ្នកសម្របសម្រួលធនធានក្រុមគ្រួសារ (FRC) នឹងផ្តល់ជូនលោកអ្នក។

**ព័ត៌មានអំពីប្រាក់ចំណូលគ្រួសារ និងការចំណាយ ជាការសម្ងាត់។ វាមិនអាចមានចំពោះកម្មវិធីណាមួយផ្សេងទៀត (រដ្ឋ ឬឯកជន) ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍**

***"តើមានបញ្ហាអ្វី បើខ្ញុំផ្លាស់ប្តូរ ឬផ្ទេរទៅកម្មវិធីអន្តរាគមន៍ចាប់ផ្តើមដំបូងផ្សេងទៀត?"***

លោកអ្នកនឹងត្រូវផ្តល់ជូនព័ត៌មានអំពីទំហំគ្រួសារ ប្រាក់ចំណូល និងការធានារ៉ាប់រងក្រុមគ្រួសាររបស់អ្នកចំពោះកម្មវិធី EI ថ្មី និងផ្តល់ជូនការយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងដោយក្រុមហ៊ុនឯកជន ឬដោយរដ្ឋរបស់អ្នក ដើម្បីដើម្បីជួយបង់ថ្លៃសេវាកម្មសម្រាប់កម្មវិធីថ្មីនេ